ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦៦/១១-អ៊ិន ហាន ស៊ុង ( អតីត ដាយ យ៉ាំង ២ )**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **សុខ ម៉ាធឿង**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន អ៊ិន ហាន ស៊ុង ហ្គាមេន ( អតីតក្រុមហ៊ុន ដាយ យ៉ាំង ២ )**

អាសយដ្ឋាន : ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១១ ៩៧៥ ៤២៧ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ហាន់ ឌីហ៊ី នាយកក្រុមហ៊ុន

២- លោក សិង្ហ សារិន ប្រធានរដ្ឋបាល

៣- លោក ចាប ផេង អ្នកបកប្រែ

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពកម្មករកម្ពុជា**

- **សហជីពកម្មករកម្ពុជារោងចក្រ ដាយ យ៉ាំង ២ (ខេមបូឌា) ខូអិលធីឌី**

អាសយដ្ឋាន : បុរីសឡា ផ្ទះលេខ ៣០ C ផ្លូវលេខ ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

ទូរស័ព្ទ : ០១៧ ៦១៦ ៥៩៨ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សេង ម៉េងហុង មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា

២- លោក តឿ ទី ប្រធានសហជីពកម្មករកម្ពុជាប្រចាំរោងចក្រ

៣- លោក សោម សំអឿន អនុប្រធានសហជីពកម្មករកម្ពុជាប្រចាំរោងចក្រ

៤- លោក អ៊ូ ចាន់ឌីណា ជំនួយការប្រធានសហជីពកម្មករកម្ពុជាប្រចាំរោងចក្រ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនផ្តល់ថ្លៃឈ្នួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតម្នាក់ៗចំនួន ១០ ដុល្លារជារៀងរាល់ខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ថ្លៃជួលផ្ទះ និងមធ្យោបាយធ្វើដំណើរដល់កម្មករម្នាក់ៗចំនួន ១០ ដុល្លារបានឡើយ ព្រោះថា ចំពោះកម្មករធ្វើការថែមម៉ោងចាប់ពីម៉ោង ២២.០០ ឡើងទៅ ទើបក្រុមហ៊ុនមានជួលរថយន្តសម្រាប់ជូនកម្មករទៅផ្ទះ ដោយអនុវត្តតាមប្រកាសលេខ ៨០ សកបយ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩។

២- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំចំពោះកម្មករណាដែលធ្វើការបានរយៈពេលពី ៦ ខែឡើងទៅ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការឱ្យប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិតក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ គឺអនុវត្តក្នុងខែទីមួយនៃឆ្នាំបន្ទាប់។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាការបន្ថែមពីរម៉ោងដដែល នៅពេលដែលកម្មករនិយោជិតដេរមិនគ្រប់តាមកាលកំណត់របស់ក្រុមហ៊ុនក្នុងមួយសប្តាហ៍ៗ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចរក្សាការបន្ថែមពីរម៉ោងបានឡើយ នៅពេលកម្មករដេរមិនបានគ្រប់ចំនួនតាមកាលកំណត់ក្នុងមួយសប្តាហ៍ម្តង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៨០ កប/អក/វក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ។

## សវនាការ និង សវនិមនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីព កម្មករកម្ពុជា លេខ ៣២០៣/១១ សសកក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំ អលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយ វិវាទការងាររួមនេះ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៦ ខែឧសភាឆ្នាំ២០១១ ដោយទទួលបានលទ្ធផល សះជានឹងគ្នាចំនួន ០៩ ចំណុច និងមិនសះជាចំនួន ០៣ ចំណុច លើការទាមទារចំនួន ១២ ចំណុច ។ ចំណុចវិវាទដែល មិនសះជានឹងគ្នាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៥៨០ ក.ប/អក/វ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគី និយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ នៅ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន ព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចវិវាទទី២ និងចំណុច វិវាទទី៣ ចំណុចមិនសះជា ០១ ចំណុច គឺចំណុចវិវាទទី១ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទមិនសះជាចំនួន ០១ ចំណុចខាង លើ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**តស្លុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ទត្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន អ៊ិន ហាន ស៊ុង ហ្គាមេន លេខ ៥៦៧៦ ពណ.ចបព ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០។

២- ប័ណ្ណប៉ាតង់ឆ្នាំ២០១០ លេខ DLT 031660.2010 ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករកម្ពុជារោងចក្រ ដាយ យ៉ាំង ២ (ខេមបូឌា) ខូអិលធីឌី លេខ ២១៤៤ កប/វក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១។

២- លិខិតលេខ ១២៣ កប ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ បញ្ជាក់ពីការចុះបញ្ជិកាពេញលក្ខណៈច្បាប់របស់សហជីពកម្មករកម្ពុជារោងចក្រ ដាយ យ៉ាំង ២។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ដាយ យ៉ាំង ២ លេខ ៥៨០ កប/អក/វក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ដាយ យ៉ាំង ២ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញនាយកក្រុមហ៊ុន ដាយ យ៉ាំង ២ (អ៊ិនហានស៊ុង ហ្គាមេន) ចូលរួមសវនាការលេខ ៣៨៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១។

២- លិខិតអញ្ជើញសហជីពកម្មករកម្ពុជាប្រចាំរោងចក្រ ដាយ យ៉ាំង ២ ចូលរួមសវនាការលេខ ៣៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- រោងចក្រ អ៊ិន ហាន ស៊ុង ហ្គាមេន មានជួលកម្មករនិយោជិត សរុបប្រមាណ ៤៣០ នាក់។

- សហជីពកម្មករកម្ពុជារោងចក្រ ដាយ យ៉ាំង ២ ជាដើមបណ្ដឹងក្នុងរឿងនេះ មានសមាជិកប្រមាណ ១១០ នាក់ ហើយសមាជិកដែលក្រុមហ៊ុនកាត់ភាគទានដោយផ្ទាល់ មាន ៣០នាក់។ សហជីពនេះមិនមានបញ្ជិកា បញ្ជាក់ពីភាពជាតំណាងបំផុតទេ។
- ភាគីក្រុមហ៊ុន អ៊ិន ហាន ស៊ុង ទទួលស្គាល់ថា សហជីពកម្មករកម្ពុជារោងចក្រ ដាយ យ៉ាំង ២ ពិតជាសហជីព នៅក្នុងក្រុមហ៊ុន អ៊ិន ហាន ស៊ុង ពិតមែន ហើយឈ្មោះក្រុមហ៊ុន បានប្ដូរពីក្រុមហ៊ុន ដាយ យ៉ាំង ២ មកជាក្រុមហ៊ុន អ៊ិន ហាន ស៊ុង ដោយមានវិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ពីក្រសួងពាណិជ្ជកម្ម លេខ ៥៦៧៥ ពណ.ចបព ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១០។

**ចំណុចវិវាទទី១: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ ដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ**

- ការអនុវត្តនៅក្នុងក្រុមហ៊ុន អ៊ិន ហាន ស៊ុង គឺក្រុមហ៊ុនមិនមានការផ្ដល់ជូនកម្មករនិយោជិតនូវ ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ ដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ទេ ហើយ ក៏មិនមានកិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីបញ្ហានេះដែរ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារឱ្យក្រុមហ៊ុនផ្ដល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ ដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ថា ដោយសារតែកម្មករនិយោជិតមួយចំនួនមានស្រុកកំណើតនៅឆ្ងាយពីរោងចក្រ ដូចជា នៅខេត្ត តាកែវ និងខេត្ត កំពង់ស្ពឺ ជាដើម។ ពួកគាត់ត្រូវជួលឡានជិះទៅធ្វើការ ឬជួលផ្ទះនៅជិតរោងចក្រ ដែលកម្មករនិយោជិតម្នាក់ត្រូវចំណាយប្រាក់ថ្លៃឈ្នួលឡាន ១២ដុល្លារអាមេរិកក្នុងមួយខែ ឬ៧ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់ថ្លៃឈ្នួលផ្ទះ គិតទាំងថ្លៃទឹកភ្លើងផង។
- ភាគីនិយោជកបញ្ជាក់ថា មិនអាចផ្ដល់ជូនកម្មករនិយោជិតតាមការទាមទារបានទេ ព្រោះក្រុមហ៊ុន មិនទាន់មានលទ្ធភាព ដោយហេតុថា រោងចក្រមានទ្រង់ទ្រាយតូច និងទទួលការងារបន្តពីរោងចក្រផ្សេង ដោយមិនមានអ្នកបញ្ជាទិញដោយផ្ទាល់ទេ។

## ហេតុផលនៃសេចក្ដីសម្រេច:

**ចំណុចវិវាទទី១: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ ដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ**

យោងតាមអង្គហេតុ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន ផ្ដល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ គឺមិនមានចែងក្នុងកិច្ចព្រមព្រៀង ឬ

អនុសញ្ញារួមណាមួយ ហើយអត្ថប្រយោជន៍នេះ ក៏មិនមានចែងក្នុងច្បាប់ដែរ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ ជាវិវាទអំពីផលប្រយោជន៍ ។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ ។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៤-អេវើគ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ០៩/០៥-គីន តាយ ហេតុផលចំណុចវិវាទទី២, លេខ ១៣៥/០៧-វិល ស៊ិន ហេតុផលចំណុចវិវាទទី១, លេខ ១៤/០៨-ឃ្វីក ស៊ូ ហេតុផលចំណុចវិវាទទី៣, លេខ ៤២/០៩ ហេតុផលចំណុចវិវាទទី២ និងលេខ ០២/១១-ពូ យៀន ហេតុផលចំណុចវិវាទទី២*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់គុណវុឌ្ឍិផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពកម្មករកម្ពុជានៅក្រុមហ៊ុន អ៊ិន ហាន ស៊ុង នេះ មិនទាន់មានភាពជាតំណាងបំផុតនៅឡើយទេ ។

សហជីពកម្មករកម្ពុជានៅក្រុមហ៊ុន អ៊ិន ហាន ស៊ុង មិនមានបញ្ជិកាទទួលស្គាល់ភាពជាតំណាងបំផុតដូចចែងក្នុងមាត្រា២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា "*សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ* " ។

ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពកម្មករកម្ពុជានៅក្រុមហ៊ុន អ៊ិន ហាន ស៊ុង មិនទាន់មានសិទ្ធិស្របតាមផ្លូវច្បាប់ក្នុងការនាំវិវាទពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយទេ លើកលែងតែសហជីពច្រើនចូលរួមគ្នាជាក្រុម ដែលមានសមាជិកសរុបលើសពី៥០ភាគរយនៃចំនួនកម្មករនិយោជិតសរុបនៅក្នុងរោងចក្រ ឬសហជីពមានបញ្ជិកាបញ្ជាក់ពីភាពជាតំណាងបំផុត ទើបអាចទាមទារផលប្រយោជន៍សេដ្ឋកិច្ច ដោយសារថ្លៃជួលផ្ទះ និងជួលឡានឡើងថ្លៃ ដូចក្នុងករណីនេះជាដើម ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតដែលទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

# សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ :** បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនផ្ដល់ថ្លៃជួលផ្ទះស្នាក់នៅ និងមធ្យោបាយធ្វើដំណើរដល់កម្មករនិយោជិតម្នាក់ៗ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **ឈិន គិរម្យ**

ហត្ថលេខា: ---------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **លីង សុវណ្ណា**

ហត្ថលេខា: ---------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល :**

ឈ្មោះ : **សុខ ម៉ាឡឿង**

ហត្ថលេខា: ---------------------------------